# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩

## ជប៉ុនផ្តល់ជំនួយចំនួន២១៧.៣៤៦ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាល

រដ្ឋាភិបាលជប៉ុននឹងផ្តល់ជំនួយតាមរយៈគម្រោងសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន*កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូច/សន្តិសុខមនុស្សជាតិ ជំនួយ"គូសាណូណេ"* ដែលមានទឹកប្រាក់សរុបចំនួន**២១៧.៣៤៦ ដុល្លារអាមេរិក** ដល់អង្គការទទួលជំនួយចំនួន៣។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តម កាត់ស៊ឹហ៊ីរ៉ូ ស៊ីណូហារ៉ា** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ជាមួយអ្នកតំណាងមកពីអង្គការទទួលជំនួយដើម្បីអនុវត្តគម្រោងដូចខាងក្រោម:

### ១-គម្រោងសាងសង់មន្ទីរពិសោធន៍វិទ្យាសាស្ត្រ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល (៨៤.៩៣៤ដុល្លារអាមេរិក)

**អង្គការទទួលជំនួយ:** មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ **ហ៊ុន សែន** ខេត្តកណ្តាល

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ **ហ៊ុន សែន** ខេត្តកណ្តាល នឹងសាងសង់អាគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នង ដើម្បីផ្តល់កន្លែងសិក្សាឱ្យបានល្អប្រសើរដល់សិស្សសិក្សាផ្នែកវិទ្យាសាស្ត្រប្រមាណ ២១២នាក់ ជាអ្នកដែលនឹងត្រូវផ្តល់ការអប់រំផ្នែកវិទ្យាសាស្ត្រមានគុណភាពខ្ពស់នៅតាមបណ្តាអនុវិទ្យាល័យពួកគេ នៅក្នុងខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និង ខេត្តកំពង់ឆ្នាំង ទីដែលសិស្សអនុវិទ្យាល័យប្រមាណជាង ១២៥,០០០នាក់ រំពឹងថានឹងទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រដែលមានគុណភាពល្អប្រសើរ។ បន្ថែមពីនេះមជ្ឈមណ្ឌលរំពឹងថាការបណ្តុះបណ្តាលគ្រូបង្រៀនគឺជាផ្នែកមួយនៃគម្រោងសហប្រតិបត្តិការបច្ចេកទេសជាមួយអង្គការ JICA ។

### ២-គម្រោងសាងសង់មន្ទីរពិសោធន៍វិទ្យាសាស្ត្រ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ (៨៥.៤២០ដុល្លារអាមេរិក)

**អង្គការទទួលជំនួយ:** មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ

ជាមួយជំនួយនេះ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ នឹងសាងសង់អាគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នងផងដែរ ដើម្បីផ្តល់កន្លែងសិក្សាដល់សិស្សសិក្សាផ្នែកវិទ្យាសាស្ត្រ ប្រមាណ

១៣៨នាក់ ជាអ្នកដែលនឹងត្រូវផ្តល់ការអប់រំផ្នែកវិទ្យាសាស្ត្រនៅតាមបណ្តា ខេត្តតាកែវ ខេត្តកំពត ខេត្តកែប និង ខេត្តព្រះសីហនុ។ គេរំពឹងថាមានសិស្សអនុវិទ្យាល័យប្រមាណជាង ១០២,០០០នាក់ នឹងទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រដែលមានគុណភាពល្អប្រសើរពីគ្រូផ្នែកវិទ្យាសាស្ត្រដែលបាន បញ្ចប់ការសិក្សាពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវនេះ។

### ៣-គម្រោងសាងសង់អគារសិក្សានៅបឋមសិក្សារស្មីអង្គាញ់ ខេត្តកំពង់ធំ (៩៦.៩២២ដុល្លារអាមេរិក)

**អង្គការទទួលជំនួយ:** សហគមន៍ មិត្តភាព អាស៊ី ខ្មែរ

សហគមន៍ មិត្តភាព អាស៊ី ខ្មែរ នឹងសាងសង់អគារសិក្សាមួយខ្នងមាន៥បន្ទប់ ដែលត្រូវបំពាក់ ដោយគ្រឿងសង្ហារឹម នៅសាលាបឋមសិក្សារស្មីអង្គាញ់ក្នុងខេត្តកំពង់ធំ។ ជាមួយនឹងជំនួយនេះ អង្គការទទួលជំនួយ នឹងត្រូវសាងសង់បង្គន់អនាម័យមួយខ្នងមាន៤បន្ទប់ផងដែរ នៅសាលាបឋម សិក្សានេះ។ គម្រោងនឹងអាចធ្វើឱ្យបរិស្ថាននៃការសិក្សារបស់សិស្សជាង ២៣៥នាក់ ល្អប្រសើរ។

*ជំនួយឥតសំណង "គូសាណូណេ" របស់ជប៉ុន* បានចាប់ផ្តើមឡើងនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ដើម្បីជួយឧបត្ថម្ភដល់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ និង ស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិត មូលដ្ឋាន។ ជំនួយនេះ មានគោលដៅគាំពារជនដែលងាយរងគ្រោះពីកត្តាផ្សេងៗ ដូចជា ភាពក្រីក្រ ភាពអកុសលផ្សេងៗ ដែលគម្រាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបជាង **៤២,៩លានដុល្លារអាមេរិក** ដល់ អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលអនុវត្តគម្រោងចំនួន ៤២៥គម្រោង នៅទូទាំងប្រទេស កម្ពុជា។

---

*ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣ ២១៧ ១៦១- ទូរសារ: ០២៣ ២១៤ ៣៣០*
*អ៊ីម៉ែល:* keikyou.eojc@online.com.kh
*គេហទំព័រ:* http://www.kh.emb-japan.go.jp